ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៣១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកំណត់ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ទំហំ ៣ ២៣៩,៧ ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

កាត់ផ្ទៃដីចំនួន ២ ទីតាំង ទំហំ១៥១ ៤២០ (មួយរយហាសិបមួយពាន់បួនរយម្ភៃ) ម៉ែត្រក្រឡា ក្នុងនោះទីតាំងទី ១ ទំហំ ៣២ ៨៣៣ (សាមសិបពីរពាន់ប្រាំបីរយសាមសិបបី) ម៉ែត្រក្រឡា ស្ថិតនៅភូមិកប់ស្រូវជំ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ និងទីតាំងទី ២ ទំហំ ១១៨ ៥៨៧ (មួយរយដប់ប្រាំបីពាន់ប្រាំរយប៉ែត

សិបប្រាំពីរ)ម៉ែត្រក្រឡា ស្ថិតនៅភូមិផ្សារលិច សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកំណត់ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ទំហំ ៣ ២៣៩,៧ ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ។

**មាត្រា២ ._**

ប្រគល់ដីចំនួន ២ ទីតាំង ទំហំ ១៥១ ៤២០ (មួយរយហាសិបមួយពាន់បួនរយម្ភៃ) ម៉ែត្រក្រឡា ស្ថិតនៅភូមិកប់ស្រូវធំ សង្កាត់គោករកា និងភូមិផ្សារលិច សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ជូនឈ្មោះ **សាយ សោភា**។

**មាត្រា ៣ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៣រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ សីហា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីនិងតារាងនិយាមការឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ..១៣១..អនក្រ.បក..ចុះថ្ងៃទី..៦.....ខែ..កក្កដា..ឆ្នាំ២០២១




តារាងនិយាមការចំណុចព្រំដី

ដីទំហំ ១១៨ ៥៨៧ម²

| ID | E | N |
|---|---|---|
| 1 | 482935.2807 | 1287256.8140 |
| 2 | 482841.1841 | 1287413.0253 |
| 3 | 483337.3692 | 1287769.5850 |
| 4 | 483551.9790 | 1287716.9700 |
| 5 | 483429.8106 | 1287669.9882 |
| 6 | 483447.7557 | 1287640.1800 |

ដីទំហំ ៣២ ៨៣៣ម²

| ID | E | N |
|---|---|---|
| 1 | 480410.3628 | 1284908.5278 |
| 2 | 480308.8885 | 1284831.2175 |
| 3 | 480059.1729 | 1285154.2292 |
| 4 | 480029.7486 | 1285245.0749 |
| 5 | 480059.7610 | 1285267.9735 |
| 6 | 480276.6493 | 1284931.8791 |
| 7 | 480356.1408 | 1284992.5513 |

ផែនទីបង្ហាញទីតាំងដីសរុបទំហំ ១៥ ហិកតា ១៤ អា ២០ សង់ទីអា ស្ថិតនៅ សង្កាត់គោករកា និងសង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ
ស្នើសុំកាត់ចេញពីផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) កំណត់ដោយអនុក្រឹត្យលេខ ២០ ជូនឈ្មោះ សាយ សោភា




តារាងនិយាមកាចំណុចព្រំដី

ដីទំហំ ១១៨ ៥៨៧ម៉ែត្រ

| ID | E | N |
|---|---|---|
| 1 | 482935.2807 | 1287256.8140 |
| 2 | 482841.1841 | 1287413.0253 |
| 3 | 483337.3692 | 1287769.5850 |
| 4 | 483551.9790 | 1287716.9700 |
| 5 | 483429.8106 | 1287669.9882 |
| 6 | 483447.7557 | 1287640.1800 |

ដីទំហំ ៣២ ៨៣៣ម៉ែត្រ

| ID | E | N |
|---|---|---|
| 1 | 480410.3628 | 1284908.5278 |
| 2 | 480308.8885 | 1284831.2175 |
| 3 | 480059.1729 | 1285154.2292 |
| 4 | 480029.7486 | 1285245.0749 |
| 5 | 480059.7610 | 1285267.9735 |
| 6 | 480276.6493 | 1284931.8791 |
| 7 | 480356.1408 | 1284992.5513 |